# នីតិវិធីចុះឈ្មោះ និងការបំពេញពាក្យស្នើសុំអាហារូបករណ៍
# នៅក្នុងប្រព័ន្ធស្នើសុំអាហារូបករណ៍
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត

២០២៤

# មាតិកា

សេចក្ដីផ្ដើម

ដំណើរការសង្ខេបនៃការបំពេញពាក្យស្នើសុំអាហារូបករណ៍តាមប្រព័ន្ធឌីជីថល

របៀបនៃការចុះឈ្មោះចូលក្នុងប្រព័ន្ធស្នើសុំអាហារូបករណ៍

# សេចក្តីផ្តើម

ប្រព័ន្ធចុះឈ្មោះ (Online) សម្រាប់ស្នើសុំចូលក្នុងប្រព័ន្ធស្នើសុំអាហារូបករណ៍ត្រូវបានរៀបចំឡើងដើម្បី៖

- ផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងព័ត៌មានសិស្សានុសិស្ស និង

- ការដាក់ពាក្យស្នើសុំអាហារូបករណ៍ដែលជាការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងសេវាសាធារណៈ។

គោលបំណងនៃឯកសារណែនាំពីការចុះឈ្មោះនេះ នឹងធ្វើការពន្យល់អំពីដំណើរការ(មួយជំហានៗ)ក្នុងការបំពេញពាក្យស្នើសុំនៅក្នុងប្រព័ន្ធស្នើសុំអាហារូបករណ៍

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត**

# ដំណើរការសង្ខេប
# នៃការបំពេញពាក្យស្នើសុំអាហារូបករណ៍តាមប្រព័ន្ធឌីជីថល

**បង្កើតគណនី**

- បេក្ខជនត្រូវ បង្កើតគណនី (user account) សម្រាប់ Log in ចូលក្នុងប្រព័ន្ធចុះឈ្មោះ ដើម្បីបំពេញបែបបទសម្រាប់ស្នើសុំ។
- បន្ទាប់ពី បំពេញព័ត៌មានបានត្រឹមត្រូវ និងភ្ជាប់ឯកសារបានគ្រប់គ្រាន់ បេក្ខជនអាចធ្វើការពិនិត្យ ហើយចុច ដាក់ពាក្យ

**ដាក់ពាក្យ**

- បន្ទាប់ពីចុច ដាក់ពាក្យ ប្រព័ន្ធនឹងផ្ញើសារ ( Alert) ទៅបេក្ខជនដោយបញ្ជាក់ឱ្យរង់ចាំការឆ្លើយតបរបស់ក្រុមការងារពិនិត្យផ្ទៀងផ្ទាត់ (Sort List)

**ក្រុមការងារជូនដំណឹង**

- ក្រុមការងារនឹងទាក់ទងទៅបេក្ខជនតាមរយៈការផ្ញើសារទៅកាន់អ៊ីម៉ែល (Email) របស់បេក្ខជន
- ប្រសិនបើព័ត៌មាន និងឯកសាររបស់សិស្សានុសិស្សមានចំណុចខ្វះខាត ក្រុមការងារនឹងផ្តល់ដំណឹងដើម្បីធ្វើការកែប្រែ ឬបំពេញបន្ថែម

# របៀបចូលទៅចុះឈ្មោះ

1

- ជាដំបូងសូមចូលទៅក្នុង Browser > វាយ https://amt.ccdcvt.org
- បំពេញអ៊ីម៉ែល (Email) ប្រើប្រាស់ផ្ទាល់ខ្លួនចូលរួចចុច **បង្កើតគណនី**



# របៀបចូលទៅចុះឈ្មោះ

2

- ➢ សូមបង្កើតគណនីសម្រាប់ Log in ចូលទៅបំពេញពាក្យស្នើសុំចូលក្នុងប្រព័ន្ធស្នើសុំអាហារូបករណ៍

- ➢ ចុចពាក្យ បង្កើតគណនី នោះប្រព័ន្ធនឹងចេញរូបដូចខាងស្តាំ សម្រាប់បំពេញ

- ➢ សូមបំពេញព័ត៌មានគ្រប់ប្រអប់ទាំងអស់->បន្ទាប់ពីបំពេញអស់សូមចុចចុះឈ្មោះ



# របៀបចូលទៅចុះឈ្មោះ

3

- បន្ទាប់ពីចុចចុះឈ្មោះហើយ នឹងទទួលបានព័ត៌មានដូចខាងក្រោម
- បំពេញអ៊ីម៉ែល (Email) ដែលបានប្រើមុននេះ រួចបំពេញ លេខកូដ (Pin Code), (Pin Code SPM) ដែលទទួលបានពី អ៊ីម៉ែល (Email)
- បំពេញរួច សូមចុច ផ្ទៀងផ្ទាត់គណនី
- បង្កើតគណនីបានសម្រេច



# របៀបចូលទៅចុះឈ្មោះ

4

- ចាប់ផ្ដើមចុះឈ្មោះចូលប្រព័ន្ធស្នើសុំអាហារូបករណ៍
- ប្រើប្រាស់អ៊ីម៉ែល ( Email ) ដែលចុះឈ្មោះមុននេះ និង លេខកូដសម្ងាត់ ( Password ) ដែលទើបបង្កើតថ្មី បំពេញដូចក្នុងរូប
- រួចចុចពាក្យ ចូល ( Login )



# របៀបចូលទៅចុះឈ្មោះ

5

- អ៊ីម៉ែល ( Email ) ដែលធ្លាប់បានចុះឈ្មោះម្តងរួចមកហើយ មិនអាចប្រើប្រាស់សម្រាប់ចុះឈ្មោះស្នើសុំម្តងទៀតបានទេ
- ដូចនេះសូមកត់ចំណាំ



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ❑ អានការណែនាំ (អក្សរពណ៌ក្រហម) ឱ្យបានយល់ច្បាស់ រួចចុចសញ្ញា ធីក (☑)
- ❑ បន្ទាប់មកចាប់ផ្តើមបំពេញព័ត៌មានឱ្យបានត្រឹមត្រូវ



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- បញ្ជាក់៖ ក្រោយបំពេញព័ត៌មានផ្ទាល់ខ្លួនរួចរាល់ សូមពិនិត្យមើលផ្នែកខាងក្រោម ដែលតម្រូវឱ្យបេក្ខជនភ្ជាប់ឯកសារនានា ( ជា File PDF ) ហើយឯកសារទាំងអស់ត្រូវបញ្ជាក់នីត្យានុកូលភាព ដោយត្រូវមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានដែលមានសមត្ថកិច្ច។



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ❑ បន្ទាប់ពីបំពេញព័ត៌មានផ្ទាល់ខ្លួនរួចហើយ សូមចុចទៅ II. ព័ត៌មានគ្រួសារ និងលេខបន្តបន្ទាប់ ដើម្បីបំពេញបន្ត



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ❑ បញ្ជាក់៖ ក្នុងករណីពុំអាចវាយបញ្ចូលព័ត៌មានបាន សូមពិនិត្យឡើងវិញនូវការណែនាំ (អក្សរពណ៌ក្រហម) តើបេក្ខជនបានអាន យល់ច្បាស់ និង បានចុចសញ្ញាធីក រួចហើយឬនៅ?)
- ❑ នៅពេលបានអាន យល់ច្បាស់ និង ចុចសញ្ញាធីករួចហើយ បេក្ខជននឹងបន្តបំពេញព័ត៌មានបានជាធម្មតា។
- ❑ បំពេញរួច សូមចុចបន្តទៅលេខ III ការជ្រើសរើសសាកលវិទ្យាល័យ, IV ប្រវត្តនៃការសិក្សា V ព័ត៌មានអ្នកណែនាំ VI. សំណេរអត្ថបទ ដើម្បីបំពេញរហូតដល់ចប់



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ❑ នៅពេលដែលបេក្ខជនបំពេញរួចរាល់ ហើយចុចដាក់ពាក្យស្នើសុំ៖ បើសិនជាព័ត៌មាន ឬឯកសារភ្ជាប់ មិនបានបំពេញ ឬភ្ជាប់គ្រប់គ្រាន់ ប្រព័ន្ធនឹងបង្ហាញសារ ជាទម្រង់ដូចខាងក្រោម ទៅតាមកន្លែង/ទីតាំង ដែលមិនបានបំពេញត្រឹមត្រូវ។

- ❑ សូមបេក្ខជនទាំងអស់យកចិត្តទុកដាក់ ពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ក្នុងករណីអក្សរដាច់ អានមិនបានអស់សេចក្ដី បេក្ខជនអាចដាក់ ម៉ៅ (Mouse)/cursor នៅលើឃ្លានោះ ប្រព័ន្ធនឹងបង្ហាញឃ្លាពេញឡើងមក



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- នៅពេលដែលបេក្ខជនបំពេញព័ត៌មានរួចរាល់ សូមចុចដាក់ពាក្យស្នើសុំ
- ប៉ុន្តែនៅពេលដែលបេក្ខជនបំពេញពុំទាន់បានត្រឹមត្រូវ និងបំពេញពុំទាន់បានគ្រប់គ្រាន់ នោះប្រព័ន្ធនឹងលោតសាររំលឹកដូចខាងក្រោម



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

❑ បើបេក្ខជនពិការភាព សូមភ្ជាប់(attached)ឯកសារបញ្ជាក់ នៅទីតាំងដូចរូបខាងក្រោម៖



# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- ❑ បេក្ខជនអាចបំពេញព័ត៌មានខ្លះសិន ឬភ្ជាប់ឯកសារខ្លះសិនក៏បាន មុននឹងចុច **ដាក់ពាក្យស្នើសុំ**
- ❑ បេក្ខជនអាចចុចពាក្យ **រក្សាទុក** ដើម្បីបិទប្រព័ន្ធទុកសិន ក្នុងករណីព័ត៌មាន ឬឯកសារមិនទាន់គ្រប់គ្រាន់


ព័ត៌មានចុះឈ្មោះ | ទម្រង់ចុះឈ្មោះស្នើសុំអាហារូបករណ៍ | ព័ត៌មានរក្សាទុកបណ្ដោះអាសន្ន | ព័ត៌មានគ្រប់លក្ខខណ្ឌ

ព័ត៌មាន

រក្សាទុក | ចាកចេញ

I. ព័ត៌មានផ្ទាល់ខ្លួន | II. ព័ត៌មានគ្រួសារ | III. ការជ្រើសរើសសាកលវិទ្យាល័យ | IV. ប្រវត្តិនៃការសិក្សា | V. ព័ត៌មានអ្នកណែនាំ | VI. សំណេរអត្ថបទ

ខ្ញុំបាទឬនាងខ្ញុំបានអាននិងបញ្ជាក់អះអាងថា៖ រាល់ព័ត៌មានដែលផ្ដល់ពិតជាត្រឹមត្រូវប្រាកដមែន។
ក្នុងករណីព័ត៌មានបេក្ខជនដែលបានផ្ដល់ឱ្យចំណុចណាមួយមិនត្រឹមត្រូវ ឬមិនពិតប្រាកដ នឹងត្រូវបាត់បង់សិទ្ធិក្នុងការទទួលបានអាហារូបករណ៍

រូបថត 4X6*

គោត្តនាមនិងនាម*: កែវ មរកត — ជាអក្សរឡាតាំង*
លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន*: 100235689
ភេទ*: ស្រី — ជនជាតិ*
សញ្ជាតិ*: ខ្មែរ — ថ្ងៃខែឆ្នាំកំណើត*
អាយុ: 26 ឆ្នាំ — លេខទូរសព្ទ*
ស្ថានភាពផ្ទាល់ខ្លួន*: រៀបការ
ទីកន្លែងកំណើត*

| រាជធានី/ខេត្ត | ស្រុក/ខណ្ឌ/ក្រុង |
|---|---|
| តាកែវ | ទ្រាំង |

នៅពេលបេក្ខជនបានបំពេញព័ត៌មានគ្រប់ប្រអប់ (fields) ហើយ៖

- បេក្ខជនអាចចុច **រក្សាទុក** (សម្រាប់ត្រួតពិនិត្យមើលឱ្យច្បាស់ឡើងវិញមុននឹងដាក់ពាក្យ)
- រាល់ការចុច **ដាក់ពាក្យ** រួចហើយគឺមិនអាចធ្វើការកែប្រែទិន្នន័យបាននោះទេ

# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍




(1) គឺជាកន្លែង ដែលធ្វើការបញ្ចូលព័ត៌មានរបស់សិស្សានុសិស្ស។

(2) គឺជាកន្លែងរក្សាទុកទិន្នន័យបណ្ដោះអាសន្ន ដែលបេក្ខជនចុច រក្សាទុក ដោយ មិនទាន់បានចុច ដាក់ពាក្យ ដែលអាចឱ្យកែប្រែនូវព័ត៌មានបន្ថែមទៀតបាន។

(3) គឺជាកន្លែងបង្ហាញព័ត៌មាន ដែលប្រព័ន្ធបានត្រួតពិនិត្យផ្ទៀងផ្ទាត់រួច។

# ដំណាក់កាលបំពេញពាក្យស្នើសុំអាហារូបករណ៍

- នៅពេលដែលបេក្ខជនបានបំពេញគ្រប់លក្ខខណ្ឌ និងចុចដាក់ពាក្យ រួចរាល់ បេក្ខជននឹងទទួលបានសារបញ្ជាក់តាមរយៈ អ៊ីម៉ែល (Email) ដែលបានចុះឈ្មោះ ដែលមានខ្លឹមសារដូចខាងក្រោម៖



សមាគម សិស្ស-និស្សិតអាហារូបករណ៍
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត

# សូមអរគុណ